CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

សង្ខេបសម្រាប់
គោលនយោបាយ

ឆ្នាំ ២០១២ លេខ ០១

# ការអភិវឌ្ឍវិស័យកសិកម្ម និង បម្រែបម្រួលអាកាសធាតុនៅកម្ពុជា[១]

*លោក រស់ បានសុខ[២] លោក ណាំង ភិរុណ[២] និង លោក ឈឹម ឈុន[៣]*

## សេចក្តីផ្តើម

សេដ្ឋកិច្ចប្រទេសកម្ពុជា ពឹងផ្អែកមួយភាគធំ ទៅលើវិស័យកសិកម្ម (Wokker *et al.* 2011: 1-3)។ ប្រជាជនជាង ៨0% ពឹងអាស្រ័យទៅលើផ្ទៃដីដែលខ្លួនមាន ដូចជាធ្វើស្រែ ចិញ្ចឹមសត្វ និងដាំដំណាំផ្សេងៗ (ដំឡូងឈើ ពោត សណ្តែកសៀង សណ្តែកដី អំពៅ និងដំណាំកៅស៊ូ) ដែលជាប្រភពដ៏សំខាន់សម្រាប់ការរកប្រាក់ចំណូលនិងចិញ្ចឹមជីវិត។ ដោយកសិករត្រូវពឹងផ្អែកជាសំខាន់ទៅលើទឹកភ្លៀងក្នុងការដាំដុះ ដូច្នេះ ការធ្វើស្រែវស្សាសំខាន់ខ្លាំងណាស់សម្រាប់ជីវភាពរស់នៅតាមជនបទ។ ផលដំណាំនានាទទួលរងផលប៉ះពាល់ពីអាកាសធាតុ ជារៀងរាល់ឆ្នាំ ដូចជា របាយទឹកភ្លៀងមិនទៀងទាត់ រដូវប្រាំងកាន់តែវែង ការឡើងកម្តៅ និងគ្រោះធម្មជាតិ (ទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ) ហើយឧបសគ្គពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុទាំងនេះ បានធ្វើឲ្យខូចខាតដល់ផលិតកម្មកសិកម្ម វិនិយោគ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ក្នុងអំឡុង ១៥ឆ្នាំកន្លងទៅនេះ។ កង្វះខាតទឹក និងការបែងចែកទឹកមិនគ្រប់គ្រាន់ពីប្រព័ន្ធធារាសាស្ត្របានបង្កជម្លោះពិបាកដោះស្រាយជាច្រើន ក្នុងចំណោមកសិករ (Nang *et al.* 2011: 37-39)។ ទោះជាយ៉ាងនេះក្តី កិច្ចប្រឹងប្រែងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តធារាសាស្ត្រ នឹងជួយលើកស្ទួយផលិតកម្មកសិកម្ម ជាពិសេសដំណាំស្រូវ។

ធនធានមច្ឆជាតិ គឺជាស្បៀងសំខាន់ទី២ បន្ទាប់ពីដំណាំស្រូវ។ ដោយសារកំណើនចំនួនអ្នកនេសាទ ការកែប្រែតំបន់ដីសើមទៅជាដីដាំដំណាំ ការរេចរិលជម្រកមច្ឆជាតិបង្កមកពីការកែប្រែការប្រើប្រាស់ដីតំបន់ទីជម្រាលព្រៃឈើ ទៅជាតំបន់ដាំដំណាំកសិ-ឧស្សាហកម្ម ការសាងសង់ទំនប់វារីអគ្គិសនី រួមទាំងកត្តាប្រែប្រួលអាកាសធាតុ ពិសេស របបទឹកភ្លៀងមិនប្រក្រតីនិងការប្រែប្រួលរបបជលសាស្ត្រ ទាំងអស់នេះបានប៉ះពាល់ដល់ផលស្តុកត្រី ហើយនឹងបន្តបង្កការលំបាកដល់ការគ្រប់គ្រងធនធានជលផលឲ្យមាននិរន្តរភាព។

ព្រៃឈើគឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណូល និងការទ្រទ្រង់ជីវភាព ជាពិសេសសម្រាប់ ជនជាតិដើម និងប្រជាជនរស់នៅតាមតំបន់ព្រៃនានា ហើយវាចាំបាច់បំផុតសម្រាប់ការការពារបរិស្ថាននិងជីវចម្រុះ និងការរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ទោះយ៉ាងនេះក្តី ការពង្រីកផ្ទៃដីដាំដុះ បានបង្រួមផ្ទៃដីព្រៃបន្តិចម្តងៗ និងធ្វើឲ្យរេចរិលដល់ធនធានព្រៃឈើ។

អត្ថបទនេះ ផ្តោតលើស្ថានភាពវិស័យកសិកម្មក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ ដើម្បីកំណត់ពីសក្តានុពលនៃផលិតកម្មថ្នាក់ជាតិ សំដៅជួយធានាសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ។ រដ្ឋាភិបាលកម្ពុជាបានឆ្លើយតប ដោយរៀបចំនូវផែនការសកម្មភាព នៃកម្មវិធីបន្សាំនឹងបម្រែបម្រួលអាកាសធាតុថ្នាក់ជាតិ ដើម្បីដោះស្រាយតម្រូវការបន្ទាន់ និងកង្វល់នៅថ្នាក់មូលដ្ឋាន ព្រមទាំងផ្តល់ជាគោលការណ៍សម្រាប់ការអនុវត្តគំនិតផ្តួចផ្តើមបន្សាំនានា សំដៅពង្រឹងភាពមាំមួននៃវិស័យកសិកម្មនិងជួយសម្រាលផលប៉ះពាល់អំពីបម្រែបម្រួលអាកាសធាតុ។ ក្នុងពេលជាមួយគ្នា ផែនការនេះក៏នឹងជួយឲ្យកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ផ្តល់ផលប្រយោជន៍បានច្រើនជាអតិបរមា ឈានទៅសម្រេចបានកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលវែង។

## គោលបំណង និងវិធីសាស្ត្រ

ការសិក្សានេះ មានគោលដៅប្រមូលផ្តុំព័ត៌មាន ដើម្បីឆ្លុះបញ្ចាំងពីទំហំកិច្ចប្រឹងប្រែងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ និងធ្វើការស្វែងយល់ស៊ីជម្រៅ ក្នុង

១ អត្ថបទសម្រាប់គោលនយោបាយសង្ខេបនេះ ដកស្រង់ចេញពីឯកសារពិភាក្សាលេខ ៦៥ របស់វិទ្យាស្ថាន CDRI (២០១១) ស្តីពី *ការអភិវឌ្ឍវិស័យកសិកម្ម និងបម្រែបម្រួលអាកាសធាតុ (ករណីសិក្សាក្នុងប្រទេសកម្ពុជា)* របស់លោក រស់ បានសុខ លោក ណាំង ភិរុណ និង លោក ឈឹម ឈុន។ ឯកសារពិភាក្សានេះឆ្លុះបញ្ចាំងពី (១) របៀបអនុវត្តកសិកម្ម និងបច្ចេកវិទ្យាកសិកម្ម ក្នុងការកំណត់សក្តានុពលផលិតកម្មថ្នាក់ជាតិ ដើម្បីធានាសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ និង (២) យុទ្ធសាស្ត្របន្សាំក្នុងការឆ្លើយតបនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងការប្រើប្រាស់ដី ក្នុងបរិបទនៃកិច្ចប្រឹងប្រែងថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។

២ អ្នកស្រាវជ្រាវក្នុងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI

៣ អ្នកស្រាវជ្រាវក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទ កសិកម្ម និងភាពក្រីក្រ នៃវិទ្យាស្ថាន CDRI

បំណងលើកកម្ពស់សន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ ហើយលទ្ធផលទទួលបាន អាចដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្របន្សាំ ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម។

ការរចនារៀបចំការស្រាវជ្រាវរួមមាន (១) ពិនិត្យឯកសារដែលមានស្រាប់ និងកំណត់ពីកង្វះខាតចំណេះដឹងផ្សេងៗ ហើយយកលទ្ធផលមកប្រើ សម្រាប់ជួយណែនាំដល់ការចុះសិក្សាដល់កន្លែង (២) ចុះប្រមូលព័ត៌មានដល់កន្លែង តាមរយៈការជជែកពិភាក្សាជាក្រុម និងការពិនិត្យសង្កេតរបស់អ្នកស្រាវជ្រាវ (៣) ធ្វើសិក្ខាសាលាពិគ្រោះយោបល់ចំនួនពីរលើកនៅកម្រិតបច្ចេកទេស និងនៅកម្រិតគោលនយោបាយ ជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីទទួលបានមតិយោបល់សំខាន់ៗអំពីដំណើរការអភិវឌ្ឍន៍កសិកម្ម ការទប់ទល់នឹងបញ្ហាផ្សេងៗដែលអាចចោទឡើងដោយសារការប្រើប្រាស់ដី និងការប្រែប្រួលអាកាសធាតុ។

## ខ្លឹមសារសំខាន់ៗ

**ផលិតផលកសិកម្ម** ពិសេសស្រូវ និងដំណាំចម្រុងៗ ដូចជាពោត ដំឡូងឈើ សណ្តែកសៀង ជាដើម បាននឹងកំពុងកើនឡើងជារៀងរាល់ឆ្នាំ (រូបភាព ១)។ កំណើនផលិតកម្មកសិកម្មសំខាន់ខ្លាំងណាស់ ដើម្បីសម្រេចបានសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។

កំណើនផលិតកម្មស្រូវ បានរួមវិភាគទានយ៉ាងសំខាន់ដល់ការលើកកម្ពស់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។ ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា បានថយចុះពី ៣៤,៨% នៅឆ្នាំ២០០៤ មកត្រឹម ៣០,១% នៅឆ្នាំ២០០៧ ហើយកាលពីឆ្នាំ១៩៩៧ ភាពក្រីក្រមានដល់ ៣៦% (World Bank 2009: 27)។

កំណើនផលិតផលស្រូវ បានមកជាសំខាន់ពីការពង្រីកផ្ទៃដីស្រូវវស្សា ជាជាងការធ្វើប្រពលវប្បកម្ម (MAFF 2011) រីឯស្រូវប្រាំង រួមវិភាគទានបានត្រឹម ១៤% នៃផលិតផលស្រូវសរុប។ ភ្លៀងធ្លាក់មិនទៀងទាត់ នឹងប៉ះពាល់ដោយចៀសមិនរួច ទៅលើផលិតកម្មស្រូវវស្សា និងដំណាំឯទៀតៗ។ ដូច្នេះ ទឹកបានពីប្រព័ន្ធធារាសាស្ត្រ មានសារៈសំខាន់ណាស់សម្រាប់ដំណាំស្រូវ។

រូបភាព ១៖ ផលិតផលប្រចាំឆ្នាំនៃដំណាំចម្រុងៗ ពីឆ្នាំ១៩៨០-២០១០




*ប្រភព៖ MAFF 2010, 2011a; NIS 2008*

រូបភាព ២៖ ផលិតផលត្រីប្រចាំឆ្នាំ ១៩៨០-២០១០




*ប្រភព៖ FiA 2009, 2010*

**ផលនេសាទ** ត្រីសមុទ្រ និងត្រីទឹកសាបចាប់បាន កើនឡើងប្រចាំឆ្នាំ ពិសេសក្នុងអំឡុង ១០ឆ្នាំកន្លងទៅ (រូបភាព ២)។ នាបច្ចុប្បន្ន ការនេសាទសមុទ្រមានច្រើនលើសពីលទ្ធភាពស្តុកត្រីដែលមានស្រាប់ ក្នុងការពងកូនតាមធម្មជាតិបំពេញចំនួនមកវិញ ហើយកូតតាចាប់ត្រី ក៏គួរសិក្សាវាយតម្លៃឡើងវិញដែរ ដើម្បីគ្រប់គ្រងធនធានជលផល ឲ្យមាននិរន្តរភាព។ ការរេចរិលតំបន់ដីសើម ព្រៃលិចទឹក និងជម្រកសមុទ្រ ដូចជាព្រៃកោងកាង ស្មៅសមុទ្រ និង ផ្កាថ្ម គឺជាក្តីកង្វល់មួយយ៉ាងធំសម្រាប់ការគ្រប់គ្រងធនធានជលផល។

**ធនធានព្រៃឈើ** សំខាន់ជាខ្លាំងសម្រាប់ជីវភាពរស់នៅ និងបរិស្ថាន។ គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា បានសង្កត់ធ្ងន់លើគោលនយោបាយព្រៃឈើថ្នាក់ជាតិ ដែលត្រូវរក្សាព្រៃឈើឲ្យបានយ៉ាងហោចណាស់ ៦០% នៃផ្ទៃដីទាំងមូល នៅឆ្នាំ២០១៥។ តាមរបាយការណ៍រដ្ឋបាលព្រៃឈើឆ្នាំ២០១០ គម្របព្រៃឈើនៅឆ្នាំ២០១០ មានប្រមាណតែ ៥៦,៩៤% ប៉ុណ្ណោះ។ ដូច្នេះ គោលនយោបាយព្រៃឈើថ្នាក់ជាតិ ជាកម្លាំងជំរុញមួយដ៏សំខាន់ ដើម្បីស្តារវិស័យព្រៃឈើឡើងវិញ។

## ឧបសគ្គនៃបម្រែបម្រួលអាកាសធាតុចំពោះវិស័យកសិកម្ម

គណៈកម្មាធិការទន្លេមេគង្គ បានបង្ហាញថា សីតុណ្ហភាពមធ្យមនៅកម្ពុជា កើនឡើង ០,៨អង្សាសេ គិតពីឆ្នាំ១៩៦០ ដល់ ២០០៥ (MRC 2010)។ គេគន់គូរថា សីតុណ្ហភាពមធ្យម ត្រូវកើនបន្ថែមពី ០,៣ ទៅ ០,៦អង្សាសេ ដល់ឆ្នាំ២០២៥ និងកើនពី ១,៤ ទៅ ៤,៣អង្សាសេ ដល់ឆ្នាំ២០៩០។ កម្តៅរំពឹងថា នឹងកើនខ្លាំងចាប់ពីខែធ្នូ ដល់ខែមិថុនា។

ប្រទេសកម្ពុជា ជារឿយៗ ត្រូវរងគ្រោះដោយការរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ។ ជាឧទាហរណ៍ ការខូចខាតបង្កដោយព្យុះកេតសាណាក្នុងឆ្នាំ២០០៩ មានប្រមាណ ១៣២លានដុល្លារអាមេរិក។ គ្រោះទឹកជំនន់ បានបង្កការខូចខាតមានតម្លៃពី ១០០ ទៅ ១៧០លានដុល្លារអាមេរិក ក្នុងឆ្នាំនីមួយៗ (RGC 2009)។

គ្រោះធម្មជាតិបានកើតមានឡើងកាន់តែញឹកញាប់ ក្នុងអំឡុងពីរ-បីទសវត្សរ៍កន្លងមកនេះ។ គ្រោះទឹកជំនន់ធំៗ កើតមានឡើងក្នុងឆ្នាំ ១៩៨៤ ១៩៩៦ និង ២០០០ ដោយបង្កការខូចខាតដំណាំស្រូវអស់ពី ៤០ម៉ឺន ទៅ ៤៥ម៉ឺនហិកតា។ ទន្ទឹមគ្នានេះ គ្រោះរាំងស្ងួតធ្ងន់ធ្ងរ បានកើតឡើងក្នុងឆ្នាំ ១៩៩៤ ១៩៩៧ ១៩៩៨ និង ២០០៤ ដោយបានបំផ្លាញដំណាំស្រូវអស់ពី ២៥ម៉ឺន ទៅ ៤០ម៉ឺនហិកតា (MAFF 2010b)។

ការគួបផ្សំផលប៉ះពាល់នៃគ្រោះរាំងស្ងួត និងទឹកជំនន់ បានធ្វើឲ្យជីវភាពជនក្រីក្រកាន់តែលំបាកខ្លាំង ហើយប្រជាជននៅជនបទជួបការលំបាកខ្លាំងជាងគេ ក្នុងការលើកស្ទួយជីវភាពរស់នៅ។ អត្រាប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រ[៤] បានថយចុះពី ៣៦% ក្នុងឆ្នាំ១៩៩៧ ដល់ ៣៤,៨%ក្នុងឆ្នាំ២០០៤ និង ៣០,១% ក្នុងឆ្នាំ២០០៧ (RGC 2002; World Bank 2009: 27) ហើយនិន្នាការនេះ ឆ្លុះបញ្ចាំងមួយចំណែកពី ទំនាក់ទំនងរវាង គ្រោះរាំងស្ងួត ទឹកជំនន់ និងភាពក្រីក្រ ហើយមួយចំណែកទៀតពី កិច្ចប្រឹងប្រែងជំរុញការអភិវឌ្ឍកសិកម្ម ពិសេសដំណាំស្រូវ។

ផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ បម្រែបម្រួលការប្រើប្រាស់ដី គួបផ្សំនឹងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ (ដូចជា ការកសាងទំនប់វារីអគ្គិសនី និងកសិ-ឧស្សាហកម្ម) អាចបង្កការប្រែប្រួលដល់កម្រិតកម្ពស់ទឹក លំហូរជលសាស្ត្រ និងគុណភាពទឹក។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

- ផលិតផលស្រូវ បានកើនឡើង ដោយមួយភាគធំបានពីការពង្រីកផ្ទៃដីស្រូវវស្សា។ នាបច្ចុប្បន្ន ការធ្វើស្រែប្រាំងចូលរួមចំណែកបានត្រឹម ១៤% នៃផលិតកម្មស្រូវសរុប។ កង្វះខាតផ្នែកបច្ចេកវិទ្យាកសិកម្ម ការប្រើប្រាស់ទុន (ដូចជា ពូជស្រូវ ការប្រើជី និង ថ្នាំសម្លាប់សត្វល្អិត) និងការទទួលបានទឹកស្រោចស្រពមិនគ្រប់គ្រាន់ គឺជាឧបសគ្គចម្បងដល់ការកែលម្អផលិតកម្ម។
- ទិន្នផលដំណាំចម្បងៗ ដូចជា ដំឡូងឈើ ពោត អំពៅ សណ្តែកសៀង ក៏បានកើនឡើងដែរ។ ថ្លៃដំឡូងឈើមានសញ្ញាងើបឡើងវិញនៅពាក់កណ្តាលឆ្នាំ២០១១ ដែលនាំឲ្យមានការពង្រីកផ្ទៃដីដាំដុះ ពីព្រោះផលិតកម្មវាអាស្រ័យទៅលើតម្រូវការទីផ្សារ និង ថ្លៃលក់ផលិតផលដែលតែងឡើងចុះឥតឈប់។
- ផលត្រីចាប់បានប្រចាំឆ្នាំ ទាំងទឹកប្រៃ និងទឹកសាប បានកើនឡើង។ ការប្រែប្រួល របបទឹកភ្លៀង និងលំហូរជលសាស្ត្រ គួបផ្សំនឹងការប្រឹងប្រែងនេសាទ ទំនងជានឹងធ្វើឲ្យរេចរិលផលស្តុកធនធានជលផល។ ស្ថានភាពនេះតម្រូវឲ្យមានការគិតគូរជាបន្ទាន់ ដើម្បីធានានិរន្តរភាពនៃធនធានជលផល។
- ធនធានព្រៃឈើ នៅតែមានសារៈសំខាន់ចំពោះបរិស្ថាន និងជីវភាពរស់នៅក្នុងមូលដ្ឋាន ជាពិសេសប្រជាជនរស់នៅជាប់នឹងតំបន់ព្រៃឈើ ទោះបីជាវាលែងផ្តល់ផលប្រយោជន៍បានច្រើនដូចពីមុនទៀតក្តី។ ការពង្រីកដីកសិកម្មបានធ្វើឲ្យថយចុះទំហំដីព្រៃឈើ រួមទាំងដីព្រៃឈើក្នុងតំបន់ការពារធម្មជាតិផង។
- ផលិតកម្មកសិកម្ម ងាយប៉ះពាល់ខ្លាំងណាស់ដោយសារកំណើនគ្រោះធម្មជាតិ ដូចជា ការរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ ដែលអាចបង្កការខូចខាតច្រើនៗដល់ផលដំណាំពិសេសដំណាំស្រូវ និងហេដ្ឋារចនាសម្ព័ន្ធ។ គ្រោះធម្មជាតិទាំងនោះច្រើនតែប៉ះពាល់ខ្លាំងបំផុតទៅលើប្រជាជនក្រីក្រនៅជនបទ ដែលតែងមានលក្ខណៈងាយរងគ្រោះជាងគេដែរ។ ទឹកបានពីប្រព័ន្ធធារាសាស្ត្រ សំខាន់ខ្លាំងណាស់ សម្រាប់លើកស្ទួយផលិតកម្ម និងជម្នះឧបសគ្គចម្បងៗបង្កឡើងដោយរបបទឹកភ្លៀងមិនទៀងទាត់។

សរុបមក រាល់កិច្ចអភិវឌ្ឍន៍សំដៅបង្កើនផលិតកម្មកសិកម្មវាមានសារៈសំខាន់ជាសារវ័ន្ត សម្រាប់កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សន្តិសុខស្បៀង។ ប៉ុន្តែ កិច្ចប្រឹងប្រែងទាំងនេះ គួរអនុវត្តយ៉ាងណាឲ្យមានការការពារបរិស្ថានគ្រប់គ្រាន់ផង។ ម្យ៉ាងទៀត គួរចាត់វិធានការសមស្របនានា ដើម្បីធានាឲ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ការឡើងចុះថ្លៃនៅទីផ្សារ បានបង្ខំកសិករឲ្យផ្លាស់ប្តូរការដាំដុះរបស់ខ្លួន។ ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្ររូបវ័ន្តថែមទៀត នឹងបង្កើតឱកាសបានច្រើនឡើង សម្រាប់កសិកម្មប្រពលវប្បកម្ម ជាពិសេសការដាំដុះពីរឬបីដងក្នុងមួយឆ្នាំ។

## លទ្ធផលរកឃើញសម្រាប់ការរៀបចំគោលនយោបាយ

- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្ររូបវ័ន្ត ជាតម្រូវការបន្ទាន់ណាស់ ដើម្បីធ្វើប្រពលវប្បកម្មផលិតកម្មកសិកម្ម និងជួយសម្រាលឥទ្ធិពលនៃ ភាពមិនប្រក្រតីនៃបម្រែបម្រួលអាកាសធាតុ ជាអាទិ៍ របបទឹកភ្លៀងមិនទៀងទាត់ ដើម្បីធានាសន្តិសុខស្បៀងថ្នាក់ជាតិ។
- ការគ្រប់គ្រងនិងការអភិរក្សដីធ្លីសមស្រប គួរតែលើកមកពិចារណាលម្អិត ដើម្បីធានាថា កិច្ចប្រឹងប្រែងអភិវឌ្ឍន៍មិនត្រឹមតែបានគិតគូរអំពីបញ្ហាបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានការពារប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ដែលជួយទ្រទ្រង់ដល់ប្រព័ន្ធកសិកម្មទាំងមូលផង។
- ស្ថាប័នរដ្ឋ និងអាជ្ញាធរមូលដ្ឋាននានា គួរត្រិះរិះបង្កើតជាយន្តការផ្សេងៗ សម្រាប់ត្រួតពិនិត្យជាប្រចាំ និងវាយតម្លៃការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម ដើម្បីជួយឲ្យមានការបន្សាំជាអតិបរមា ជាមួយនឹងបម្រែបម្រួលអាកាសធាតុ។
- កសិករ គួរទទួលបានចំណេះដឹងបច្ចេកទេស សេវាកម្មផ្សព្វ

---

៤ ភាពក្រីក្រត្រូវបានកំណត់ជា ភាគរយនៃចំនួនប្រជាជនដែលចំណាយតិចជាង ១,២៥ដុល្លារក្នុងមួយនាក់ ក្នុងមួយថ្ងៃ ដោយគណនាតាមតម្លៃអន្តរជាតិក្នុងឆ្នាំ២០០៥ (សូចនាករនៃការអភិវឌ្ឍពិភពលោក - (http://data.worldbank.org/data-catalog/world-development-indicators, ចេញផ្សាយចុងក្រោយក្នុងខែមីនា២០១១ និងដកស្រង់យកនៅថ្ងៃទី២៧ តុលា ២០១១)។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

ផ្សាយកសិកម្ម ដូចជា ការបណ្តុះបណ្តាលពីប្រព័ន្ធស្រូវប្រពលវប្បកម្ម ការប្រើប្រាស់ជី និង ការគ្រប់គ្រងកត្តាចង្រៃតាមវិធីសាស្ត្រចម្រុះ ជាដើម ដើម្បីបង្កើនផលិតកម្មកសិកម្ម។

- គួរចាត់វិធានការសមស្របផ្សេងៗ ដើម្បីធានាការអនុវត្តគំនិតផ្តួចផ្តើមនានាប្រកបដោយប្រសិទ្ធភាពខ្ពស់ អាចឆ្លើយតបបានតាមគោលបំណងនៃគោលនយោបាយជាតិ ជាពិសេសគោលនយោបាយគ្រប់គ្រងព្រៃឈើ និងយុទ្ធសាស្ត្របន្សាំរយៈពេលវែង សម្រាប់ការអភិវឌ្ឍកសិកម្ម។

## ឯកសារយោង

Chheng K. (2010), presentation at the International Conference on "Managing Forest Resources for Multiple Ecosystem Services under Robust and Fragile Environment" (Phnom Penh: FA)

Fisheries Administration (2009), "Overall Annual Report on Fisheries to 2009 and targeting for 2010" (Khmer version) (Phnom Penh: FiA)

Fisheries Administration (2010), "Overall Annual Report on Fisheries to 2010 and Targeting to 2011" (Khmer version) (Phnom Penh: FiA)

MAFF (2010a), "Annual Report of Ministry of Agriculture, Fishery and Forestry for 2009-2010 and direction for 2010-2011" (Phnom Penh: MAFF)

MAFF (2010b), Conference handout on the Assessment of Vulnerability and Adaptation to Climate Change, Sunway Hotel on 26 May 2010 (Phnom Penh: MAFF)

MAFF (2011), "Annual Development Report for 2010-2011 and Target for 2011-2012" (Phnom Penh: MAFF)

MRC (2010), *Climate Change Baseline Assessment*, Working Paper II, http://www.mrcmekong.org/ish/SEA-Baseline/7-Climate-change-baseline-assessment.pdf (accessed 08 June 2011) p. 7

Nang Phirun, Khiev Daravy, Philip Hirsch & Isabelle Whitehead (2011), *Improving the Governance of Water Resources in Cambodia: A Stakeholder Analysis*, Working Paper Series No. 54 (Phnom Penh: CDRI)

NIS (2008), *Statistical Yearbook of Cambodia 2008* (Phnom Penh: MoP)

RGC (2002), "National Poverty Reduction Strategy 2003-2005" (Phnom Penh: RGC)

RGC (2009), Post Disaster Needs Assessment at a Glance 2009: Ketsana storm and floods, September and October 2009, http://www.gfdrr.org/gfdrr/sites/gfdrr.org/files/ Cambodia_PDNA_GLANCE.pdf (accessed 16 March 2011)

Ros Bansok, Nang Phirun, Chhim Chhun (2011), *Agricultural Development and Climate Change: The Case of Cambodia*, Working Paper Series No. 65 (Phnom Penh: CDRI)

Wokker, C., P. Santos, Ros Bansok & K. Griffiths (2011), *Irrigation Water Productivity in Cambodian Rice System*, Working Paper Series No. 51 (Phnom Penh: CDRI)

World Bank (2009), "Sustaining Rapid Growth in a Challenging Environment, Cambodia Country Economic Memorandum", www.worldbank.org/kh (Phnom Penh: World Bank)